**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ២៥៣៧ព.ណ...គ.ព.

ថ្ងៃ ព្រហស្បតិ៍ ១រោច ខែ ភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ ៩ ឆ្នាំ ២០២០

# សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ ឧកញ៉ា លោក លោកស្រីដែលជាម្ចាស់សហគ្រាស ផលិតករ សេវាករ ពាណិជ្ជករ និងសាធារណជនទូទៅឲ្យបានជ្រាបថា៖ ក្រុមប្រឹក្សាជំរុញការនាំចេញវិស័យវាយនភណ្ឌ Synthetic & Rayon Textiles Export Promotion Council (SRTEPC) នឹងរៀបចំពិព័រណ៍ " **The 5th Edition of Source India 2020** " តាមរយៈវេទិកាអេឡិកត្រូនិក (ពិព័រណ៍អនឡាញ) ដែលប្រព្រឹត្តទៅចាប់ពីថ្ងៃទី០៧ ដល់ ០៩ ខែកញ្ញា ឆ្នាំ២០២០។

ព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្មអនឡាញនេះនឹងមានសមាជិកអ្នកនាំចេញប្រហែល១០០ក្រុមហ៊ុន នៃក្រុមប្រឹក្សាជំរុញការនាំចេញវិស័យវាយនភណ្ឌឥណ្ឌា (SRTEPC) មកតាំងបង្ហាញនូវបច្ចេកវិទ្យាថ្មីៗ ខ្សែចង្វាក់ផលិតកម្ម និងផលិតផលវាយនភណ្ឌចុងក្រោយបង្អស់ដែលមានដូចជា អំបោះ កប្បាស កំណាត់ និងប្រភេទសាច់កំណាត់ សម្រាប់ការពារជំងឺកូវីដ-១៩ ផងដែរ។ ពិព័រណ៍ពាណិជ្ជកម្មនេះត្រូវបានចាត់ទុកជា វេទិកាជំនួបពាណិជ្ជកម្មតាមរយៈអនឡាញ អ្នករៀបចំកម្មវិធីនឹងអញ្ជើញអ្នកទិញចូលរួមប្រមាណ ២៥០ក្រុមហ៊ុន មកពី ៥០ប្រទេសក្នុងគោលបំណងជំរុញការផ្សព្វផ្សាយផលិតផល និងសេវាកម្មរបស់ខ្លួនព្រមទាំងជាឱកាសល្អក្នុងការទទួលយកនូវចំណេះដឹង បច្ចេកវិទ្យាថ្មីៗនៃវិស័យឧស្សាហកម្មវាយនភណ្ឌតាមរយៈសន្និសីទវីដេអូ (Video Conferences) ។

អាស្រ័យដូចបានជម្រាបជូនខាងលើ ដំណឹងនេះចាត់ទុកដូចជាការអញ្ជើញ ឧកញ៉ា លោក លោកស្រីដែលជាម្ចាស់សហគ្រាស ផលិតករ ពាណិជ្ជករ សេវាករ និងម្ចាស់ក្រុមហ៊ុនវិនិយោគ ដែលកំពុងធ្វើធុរកិច្ចលើវិស័យវាយនភណ្ឌ ហើយមានបំណងចង់ចូលរួមផ្សព្វផ្សាយពី ផលិតផល ឬ សេវាកម្មរបស់ខ្លួន ឬមានគម្រោងស្វែងរកដៃគូពាណិជ្ជកម្មក្នុងព្រឹត្តិការណ៍ពិព័រណ៍នេះ សូមចុះឈ្មោះចូលរួមតាមអនឡាញតាមរយៈគេហទំព័រ:https://sourceindia.srtepc.in ។

សូមអរគុណ។

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

KINGDOM OF CAMBODIA

Nation - Religion - King

Ministry of Commerce

N° 2737MOC 9/EA

Phnom Penh, 3 September, 2020

## ANNOUNCEMENT

The Ministry of Commerce of the Kingdom of Cambodia has the honor to inform all producers, traders, service providers and entrepreneurs that Synthetic & Rayon Textiles Export Promotion Council (SRTEPC) is organizing **"The 5th Edition of Source India 2020"** on Virtual platform from 7th - 9th September, 2020 with the support of Ministry of Commerce & Industry and Ministry of Textiles, Government of India.

This platform, around 100 member-exporters of the Council will be exhibiting their latest range of synthetic and rayon textile items including Fiber, Yarn, Fabrics, Home Textiles, Made-ups, Technical Textiles & Covid Protective Fabrics.

The Meet is on virtual platform and the council has planned to invite over 250 leading buyers of MMF Textiles from around 50 countries including Cambodia to Source India 2020. The traders will have an opportunity to showcase their latest range of textile items under the virtual platform of SRTEPC, and interact with senior representatives of leading India companies and include profitable business deals through chat/video conferences.

In this regard, the Ministry of Commerce would like to invite all entrepreneurs, producers, traders, service providers and investment companies of which their business activities are related to textiles industries to participate the above event. For more information on registration, interested participants may please visit the website of (SRTEPC): http://sourceindia.srtepc.in.

THANK YOU!